មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីប្រកាសព័ត៌មាន

## របាយការណ៍ប្រចាំឆ្នាំ៖ ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា

ភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៤

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) សូមចេញផ្សាយនូវរបាយការណ៍លម្អិតប្រចាំឆ្នាំស្តីពីស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅក្នុងប្រទេសកម្ពុជា។ របាយការណ៍នេះតាក់តែងឡើង ដោយគម្រោងគាំពារប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅកម្ពុជា ដែលខ្លឹមសារនៅក្នុងរបាយការណ៍បានវិភាគលម្អិតអំពីស្ថានភាពកម្រិតនៃការអនុវត្តសិទ្ធិ និងលទ្ធភាពដែលពលរដ្ឋអាចប្រើប្រាស់សិទ្ធិរបស់ខ្លួន អំឡុងពីថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០២៣ រហូតដល់ ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០២៤។

របាយការណ៍នេះពិនិត្យទៅលើទិដ្ឋភាពនៃការវិវឌ្ឍន៍ និងបញ្ហាប្រឈមនានាដែលប៉ះពាល់ដល់សេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា។ របាយការណ៍ក៏បង្ហាញពីការវិភាគលើក្របខណ្ឌច្បាប់ គោលនយោបាយ និងការអនុវត្តដែលគម្រោងបានកត់ត្រា និងចងក្រងឯកសារ អំពីករណីនៃការរឹតត្បិត ការរំលោភបំពាន និងការគំរាមកំហែងទៅលើបុគ្គល និងអង្គការនានាដែលកំពុងអនុវត្តសិទ្ធិទាំងនេះ។

របាយការណ៍នេះបង្ហាញពីកង្វះនៃការអនុលោមតាមបទប្បញ្ញត្តិច្បាប់ ដែលទើបអនុម័តថ្មីៗជាមួយនឹងស្តង់ដារអន្តរជាតិដែលធ្វើអោយរាជរដ្ឋាភិបាល អាចដាក់កំហិតនិងរឹតត្បិតសិទ្ធិរបស់ពលរដ្ឋ អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សក្នុងការអនុវត្តសេរីភាពខាងការបញ្ចេញមតិ។ ដើម្បីឆ្លើយតបនឹងការថមថយនេះ របាយការណ៍បានផ្តល់នូវអនុសាសន៍ ដល់រាជរដ្ឋាភិបាលនូវវិធានការដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដើម្បីការពារ និងលើកកម្ពស់សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា។

លោកអ្នកអាចទាញយករបាយការណ៍ទាំងមូលជាភាសាខ្មែរ និងអង់គ្លេសនៅលើវេបសាយរបស់ ម.ស.ម.ក តាមរយៈតំណភ្ជាប់នេះ៖ https://cchrcambodia.org/publications/general-reports។ របាយការណ៍នេះជារបាយការណ៍ប្រចាំឆ្នាំលើកទី៤ដែល ផលិតឡើងដោយគម្រោងគាំពារប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅកម្ពុជា។ របាយការណ៍ឆ្នាំទីមួយ ទីពីរ និង ទីបី ត្រូវបានចេញផ្សាយជាបន្តបន្ទាប់គ្នានៅក្នុងខែមេសា ឆ្នាំ២០២២ ខែវិច្ឆិកា ឆ្នាំ២០២២ និងខែវិច្ឆិកា ឆ្នាំ២០២៣។

**អំពីគម្រោង៖**

ដើម្បីឆ្លើយតបនឹងការរឹតត្បិតសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន គម្រោងគាំពារប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅកម្ពុជាមានគោលបំណងបង្ហាញពីការតាក់តែងច្បាប់ជាវិជ្ជមានដើម្បីនាំឱ្យច្បាប់កម្ពុជាមានភាពស៊ីចង្វាក់គ្នាជាមួយបទដ្ឋានច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ គម្រោងក៏ជំរុញឱ្យមានភាពចម្រុះនៃប្រព័ន្ធផ្សព្វផ្សាយតាមរយៈសារព័ត៌មានឯករាជ្យអាចធ្វើការស៊ើបអង្កេត និងរាយការណ៍គ្រប់បញ្ហាដែលជាប្រយោជន៍សាធារណៈ ដោយមិនមានការភ័យខ្លាច និងធានាថារាល់ស្ថាប័នរដ្ឋាភិបាល និងឯកជនដែលមានមុខងារសាធារណៈត្រូវអនុវត្តគោលការណ៍នៃការបង្ហាញព័ត៌មានជាអតិបរិមា។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកអ្នកសម្របសម្រួលគម្រោងគាំពារប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅកម្ពុជា លោក ហួន ផន តាមរយៈអ៊ីម៉ែល phorn@cchrcambodia.org ឬលេខទូរស័ព្ទ ០៧០ ៧៥៧ ៨៨៤។

<u>ចប់</u>

**បណ្ណាធិការ៖**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ម.ស.ម.ក" បានបង្កើតឡើងក្នុង ខែវិច្ឆិកា ឆ្នាំ២០០២ គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការលើកកម្ពស់ និងការពារលិទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក គឺជាសមាជិកនៃ អង្គការផ្លាស់ប្តូរសេរីភាពបញ្ចេញមតិអន្តរជាតិ (IFEX) ដែលជាបណ្តាញសកលសម្រាប់សេរីភាពនៃការបញ្ចេញមតិ និង CIVICUS ៖ សម្ព័ន្ធពិភពលោកសម្រាប់ការចូលរួមរបស់ពលរដ្ឋ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការប្រឆាំងទារុណកម្មពិភពលោក (MOCT SOS-Torture Network) និង ជាសមាជិក OECD Watch ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និង សេរីភាព" និងទទួលពានរង្វាន់ ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គម មកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងផ្លាស់ប្តូរសង្គម នៅសាកលវិទ្យាល័យឃ្វីនឡែនក្នុងទីក្រុងប្រ៊ីសប៊ែន (Brisbane) នៃប្រទេសអូស្ត្រាលី។